00703040

E51/13

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | 00២/១៩-0៩-២00៧-អវតក/អជសង |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២0១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 07 / 06 / 2011
ម៉ោង (Time/Heure): 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មបន្ថែមរបស់ អៀង សារី តាមវិធាន ៨៩ (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោសរបស់ព្រះមហាក្សត្រ*)**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម យូ ឧត្តរ | |

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor Koppe

លោក អាង ឧត្តម

លោក Michael G.KARNAVAS

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

លោក ស សូវាន

លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ អៀង សារី តាមរយៈមេធាវីរបស់គាត់ ("មេធាវីការពារក្តី") បានដាក់អញ្ញត្រកម្មបន្ថែម តាមវិធាន៨៩ ចំនួន២ ស្តីពីបញ្ហា "ការអនុគ្រោះទោស និងការលើកលែងទោសរបស់ព្រះមហាក្សត្រ" ("RPA") [1] និង *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ("Ne Bis In Idem")*[2]។ នៅក្នុងចម្លើយតបរួមនេះ សហព្រះរាជអាជ្ញា នៅតែរក្សាជំហររបស់ខ្លួនថា បណ្តឹងអញ្ញត្រកម្មទាំង២នេះ គួរតែត្រូវបានបដិសេធចោល។

## II. គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ

### ក. សេចក្តីផ្តើម

២- នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញមេធាវីការពារក្តីឱ្យដាក់សារណារបស់ខ្លួន ទាក់ទងទៅនឹងអញ្ញត្រកម្មពាក់ព័ន្ធនឹងគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ។ អង្គជំនុំជម្រះបានបញ្ជាក់ថា មានពីរកន្លែងដែលមេធាវីការពារក្តីត្រូវពិចារណាគឺ៖ ទី១) បញ្ហាស្តីពីថាតើការកាត់ក្តីនៅឆ្នាំ១៩៧៩ ដោយតុលាការប្រជាជនបដិវត្ត ("PRT") ត្រូវបានប្រព្រឹត្តទៅដោយស្របតាមបទដ្ឋានជាមូលដ្ឋាននៃការកាត់ក្តីដ៏ត្រឹមត្រូវ ដែរឬទេ[3], និងទី២) បើសិនជាមានសេចក្តីសំអាងថ្មី ថាតើ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne Bis In Idem)* បានកម្រិតទៅលើការលើកឡើងនៃសាលដីការបស់អង្គបុរេជំនុំជម្រះ ("អបជ") លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អៀង សារី[4] ("សាលដីកាលើបណ្តឹង ឧទ្ធរណ៍") ដែរឬទេ។

---

[1] ឯកសារលេខ **E51/10**, សារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មរបស់គាត់ដែលធ្វើតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង (ការលើកលែងទោស និងការអនុគ្រោះទោស), ថ្ងៃទី២៧ ឧសភា ២០១១, ERN 00700406-00700421 ("សារណាស្តីពី RPA") ។

[2] ឯកសារលេខ **E51/11**, សារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មរបស់គាត់ដែលធ្វើតាមវិធាន៨៩ (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ - *Ne bis in idem*), ថ្ងៃទី២៧ ឧសភា ២០១១, ERN 00700489-00700502 ("សារណាស្តីពី *Ne bis in idem*") ។

[3] ឯកសារលេខ **E51/9**, អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ការដាក់អញ្ញត្រកម្មបន្ថែម" (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ), ថ្ងៃទី១២ ឧសភា ២០១១, ERN 00687381 ។

[4] ឯកសារលេខ **D427/1/30**, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១១ មេសា ២០១១, ERN 00661785-00661994, ("សាលដីកាលើបណ្តឹងឧទ្ធរណ៍") ។

## ខ. ភាពសមស្របនៃការកាត់ក្តីនៅឆ្នាំ១៩៧៩ ជាមួយនឹងបទដ្ឋានជាមូលដ្ឋាននៃការកាត់ក្តីដ៏ត្រឹមត្រូវ

៣- នៅក្នុងសារណារបស់ខ្លួន មេធាវីការពារក្តីមិនបានប្រកាន់គោលជំហរ ថាតើការកាត់ក្តីនៅឆ្នាំ១៩៧៩ ស្របតាមបទដ្ឋានជាមូលដ្ឋាននៃការកាត់ក្តីដ៏ត្រឹមត្រូវដែរ ឬមួយយ៉ាងណានោះទេ ក្រៅតែពីបាននិយាយថាពួកខ្លួន "មិនធ្លាប់បានអះអាងថាវាជាការកាត់ក្តីគំរូមួយនោះទេ" ហើយថាវាមិនទាក់ទងទៅនឹងអង្គជំនុំជម្រះសាលាដំបូង ដើម្បីពិចារណាលើការអនុវត្តដ៏សមស្របមួយនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា("CCPC") និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") នោះទេ។ ជាការឆ្លើយតប សហព្រះរាជអាជ្ញារើសយកសេចក្តីសន្និដ្ឋានពីមុនៗរបស់ខ្លួន[5] ព្រមទាំងការយល់ឃើញនានារបស់ អបជ[6]។

៤- ការកាត់ក្តីនៅឆ្នាំ១៩៧៩ គឺមិនមែនជា "ការកាត់ក្តី" មួយនៅក្នុងន័យច្បាប់នោះទេ៖ តុលាការប្រជាជនបដិវត្ត មិនត្រូវបានបង្កើតឡើងដោយច្បាប់នោះទេ ប៉ុន្តែផ្ទុយទៅវិញត្រូវបានបង្កើតឡើង ដោយក្រឹត្យដែលមិនមាននរណាម្នាក់អាចចេញជាសេចក្តីសម្រេចនានាតាមបែប "តុលាការ" បានឡើយ។ វាមិនត្រូវបានធ្វើជាអធិបតីដោយ ចៅក្រម និងមិនដំណើរការបានដោយឯករាជ្យ និងដោយអនាគតិបានឡើយ[7]។ ហេតុដូច្នេះ វាមិនស្ថិតនៅក្នុងវិសាលភាពនៃ*គោលការណ៍គ្មានការកាត់ក្តីពីរដងចំពោះបទល្មើសតែមួយ (Ne Bis In Idem)* ដូចដែល អបជ បានប្រកាសរួចហើយ ហើយមិនស្ថិតនៅក្នុងរូបមន្តណាមួយផ្សេងទៀតនៃគោលការណ៍នេះដែរ។

៥- ទោះបីជា មេធាវីការពារក្តីមិនបានប្រកាន់យកគោលជំហរថា ការកាត់ក្តីនេះមានភាពស្របតាមបទដ្ឋានជាមូលដ្ឋាននៃការកាត់ក្តីដ៏ត្រឹមត្រូវក៏ដោយ ក៏ពួកគាត់បានធ្វើសេចក្តីសង្កេតមួយចំនួនដែរ។ ពួកគាត់បានកត់សម្គាល់ថា បញ្ហាស្តីពីការកាត់ក្តីដ៏ត្រឹមត្រូវ មិនត្រូវបានលើកឡើងទេ នៅពេលដែលមានការលើកលែងទោសឲ្យ អៀង សារី នៅឆ្នាំ១៩៩៦ បានកត់សម្គាល់ទៀតថា នៅក្នុងវិសាលភាពដែលការកាត់ក្តីនោះមានបញ្ហាផ្សេងៗ បញ្ហាទាំងនោះ គឺជាបញ្ហាដែលមានអត្ថិភាពនៅក្នុង អវតក

[5] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១៩ វិច្ឆិកា ២០១០, D427/1/17 ត្រង់លេខ ERN 00626572–3, [77]–[79] ។

[6] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ត្រង់លេខ ERN 00661855–63 ។

[7] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ត្រង់លេខ ERN 00661863 ។

សព្វថ្ងៃនេះ (ដោយឡែក គឺមានទាក់ទងទៅនឹងឯករាជ្យភាពរបស់តុលាការ), ព្រមទាំង បានកត់សម្គាល់ថា ការមិនមានការបែងចែកអំណាច គឺជាលក្ខណៈមួយតាមបែបរដ្ឋាភិបាលកុម្មុយនីស្ត ដែលកំពុងនៅមានអត្ថិភាពរហូតដល់សព្វថ្ងៃនេះ។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា បញ្ហាទាំងនេះគឺមិនពាក់ព័ន្ធទេ។

៦- មិនថា សម្តេចព្រះនរោត្តមសីហនុ ឬរដ្ឋាភិបាលកម្ពុជាឆ្នាំ១៩៩៦ បានទទួលស្គាល់ ឬមិនទទួលស្គាល់ថា ការកាត់ក្តីនោះ គឺមិនមានលក្ខណៈត្រឹមត្រូវដែរ ឬយ៉ាងណានោះទេ, ឬមួយសូម្បីតែបានផ្លាស់ប្តូរគំនិតរបស់សម្តេច ឬរបស់រដ្ឋាភិបាលចំពោះការកាត់ក្តីនោះក៏ដោយ ក៏វាមិនបានផ្លាស់ប្តូរដល់ឋានៈតាមផ្លូវច្បាប់នៃការកាត់ក្តីនោះឡើយ។ មេធាវីការពារក្តីមិនបានលើកភ័ស្តុតាងបញ្ជាក់ពីហេតុផលថា នរណាមួយក៏ដោយ ដែលថាបើចាត់ទុកថាការកាត់ក្តីនោះត្រឹមត្រូវ ហើយពួកគាត់បានលើកភ័ស្តុតាងបញ្ជាក់ពីហេតុផល ក៏ការណ៍នេះមិនបានលង់នៅក្នុងក្តីសង្ស័យណាមួយ ទៅលើភ័ស្តុតាងជាសត្យានុម័ត ដែល អបជ បានពិចារណារួចហើយនោះដែរ។

៧- ការកត់សម្គាល់របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងការបែងចែកអំណាច គឺគ្រាន់តែជាផ្នែកតូចនៃអ្វី ដែលបានធ្វើឱ្យការកាត់ក្តីនៅឆ្នាំ១៩៧៩ មិនត្រឹមត្រូវប៉ុណ្ណោះ។ មេធាវីការពារក្តីមិនបានជំទាស់ទៅនឹងការរកឃើញនានាដែលថា ពិរុទ្ធភាពរបស់ជនចាប់ចោទ ត្រូវបានក្រឹត្យច្បាប់កំណត់ទុកមុនរួចជាស្រេចហើយ, ប្រធានតុលាការ និងរយៈពេលនៃការកាត់ក្តី បានគាំទ្រដល់ទស្សនៈនៃ ការកំណត់ទុកមុនរួចជាស្រេច, សាក្សីទាំងឡាយត្រូវបានគេ "រៀបចំជាឆាក", មេធាវីការពារក្តីដែលបានចាត់តាំងបានបង្ហាញពីភាពលំអៀង និងបានធ្វើសកម្មភាពមិនសមស្រប, និងមិនមានភ័ស្តុតាងការពារខ្លួនណាមួយត្រូវបានគេដាក់បង្ហាញនោះទេ។ នៅក្នុង និងអំពីកត្តាទាំងនេះ ដោយខ្លួនឯងផ្ទាល់ បានបង្ហាញថាការកាត់ក្តីនេះ គឺមិនឯករាជ្យ ឬមិនអនាគតិ។

៨- ដូចដែលបទដ្ឋានស្តីពីការបែងចែកអំណាចបានតម្រូវ ទាំងបទដ្ឋាននៅ អវតក ក្តីឬទាំងបទដ្ឋាននៅប្រទេសចិនក្តី គឺសុទ្ធតែមិនមានការទាក់ទងនឹងការសម្រេចនេះទាំងអស់។ អបជ បានធ្វើការវាយតម្លៃអំពីភាពគ្មានឯករាជ្យភាពរបស់ចៅក្រម និងទីប្រឹក្សារបស់ប្រជាជន នាឆ្នាំ១៩៧៩ ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីថ្លែងការណ៍របស់ពួកគេអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ មុខដំណែងរបស់ពួកគេ

00703045



ដែលជារដ្ឋមន្ត្រីរបស់រដ្ឋាភិបាល និងសក្ខីកម្មរបស់ពួកគេប្រឆាំងនឹងជនជាប់ចោទ ក្នុងនាមជាជនរងគ្រោះ ឬជាសាក្សី។ បន្ថែមពីលើនេះ ពួកគេបានរកឃើញថា តុលាការត្រូវបានគេបង្កើតឡើង គឺមិនបានផ្អែកទៅតាមច្បាប់ទេ ប៉ុន្តែបែរជាផ្អែកលើក្រឹត្យរបស់អង្គការនីតិប្រតិបត្តិទៅវិញ។ ពួកគេបានធ្វើការវាយតម្លៃនេះ ដោយប្រឆាំងនឹងបទដ្ឋាននានាដែលបានបង្កើតឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្ស, មហាសន្និបាតនៃអង្គការសហប្រជាជាតិ, តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី, តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប និងតុលាការនេះ។ ប្រការដែលបទដ្ឋានទាំងនេះមិនត្រូវបានគេគោរពប្រតិបត្តិតាមជាសាកល គឺមិនបានធ្វើឲ្យឋានៈរបស់បទដ្ឋាននេះថយចុះនោះទេ។

៩- លើសពីនេះ គឺជាគំនិតវើរវាយមួយក្នុងការដែលព្យាយាមចាត់ទុកថាដូចគ្នារវាងសវនាការកាត់ទោសឆ្នាំ១៩៧៩ ជាមួយនឹងតុលាការ អវតក នេះ ដែលបានបង្កើតឡើងដោយច្បាប់។ ដោយសារថាតុលាការប្រជាជន បដិវត្តន៍ឆ្នាំ១៩៧៩ គឺមិនមែនជាតុលាការដែលត្រូវបានបង្កើតឡើង “ដោយច្បាប់” នោះទេ ប្រធានតុលាការ និងទីប្រឹក្សារបស់ប្រជាជន កាលណោះ គឺជារដ្ឋមន្ត្រីនៃរដ្ឋាភិបាល ពួកអ្នកជំនាញ និងជនរងគ្រោះ គឺជាអ្នកប្រកាសជាសាធារណៈអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ការរកឃើញទាំងនេះ និងការរកឃើញផ្សេងៗទៀតរបស់អង្គបុរេជំនុំជម្រះ ស្តីពីលក្ខណៈនៃសវនាការជំនុំជម្រះក្តីឆ្នាំ១៩៧៩ បានបង្ហាញយ៉ាងច្បាស់ថា ស្ថានភាពនៅក្នុង “តុលាការ”នោះ គ្មានលក្ខណៈដូចគ្នានឹង អវតក ឡើយ។

## គ. អំពីគោលការណ៍ស្តីពី*ការកាត់ក្តីពីរដងចំពោះបទល្មើសតែមួយ*

១០- ផ្ទុយទៅនឹងជំហរដែល អង្គបុរេជំនុំជម្រះ (អបជ) បានប្រកាន់យក មេធាវីការពារក្តីបានសន្និដ្ឋានថា បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា(CCPC) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងវិធានអន្តរជាតិស្តីពីនីតិវិធីដែលទាក់ទងនឹង គោលការណ៍គ្មាន*ការកាត់ក្តីពីរដងចំពោះបទល្មើសតែមួយ* បានហាមឃាត់មិនឲ្យកាត់ទោស អៀង សារី ទេ ។

## *បញ្ញត្តិនៃ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា*

១១- គឺជាការច្បាស់លាស់ណាស់ថា ផ្ទុយទៅនឹងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងអំពីនិយមន័យនៃ *អាជ្ញាអស់ជំនុំ* (*res judicata*) ដែលគេយកមកប្រើតែចំពោះជនដែលត្រូវបានលើកលែងការចោទប្រកាន់និងជនដែលរកឃើញថាគ្មានទោសតែប៉ុណ្ណោះ។ អបជ បានសំរេចអនុម័តយកនូវវិធីសាស្ត្រដែលត្រឹមត្រូវ ដោយសារស្របតាមន័យធម្មតារបស់មាត្រានីមួយៗនៃមាត្រាទាំងនោះ និងនៃក្រមនីតិវិធីកម្ពុជាទាំងមូល។ ដោយសារតែ អបជ[8] និងមេធាវីការពារក្ដីបានយល់ព្រមរួចហើយកាលពីនៅក្នុងពេលដាក់សារណាលើកមុន[9]មាត្រា១២បានផ្ដល់និយមន័យនៃពាក្យ *អាជ្ញាអស់ជំនុំ* តាមដូចដែលបានប្រើនៅក្នុងមាត្រា៧។ នេះគឺអាចមើលឃើញចាប់តាំងពីនៅក្នុងចំណងជើងនៃមាត្រា *អាជ្ញាអស់ជំនុំ (Res judicata)* មក ការដែលមិនមានការកំណត់និយមន័យនៅក្នុងបញ្ញត្តិណាមួយផ្សេងទៀត, ការដាក់មាត្រាដល់ទៅពីរនៅក្នុងជំពូកតែមួយជាមួយគ្នា និងពាក្យ "ដោយ<u>អនុវត្តតាម</u>គោលការណ៍"បានធ្វើឲ្យដឹងថានោះគឺជាវិធីតែមួយគត់ដែល<u>ត្រូវតែអនុវត្ត</u>គោលការណ៍<u>តាមបែបនេះ</u>។ មេធាវីការពារក្ដីមិនបានផ្ដល់មូលហេតុដែលសម្រាប់ជំនួស ថាតើហេតុអ្វីបានជាការបកស្រាយថ្មីនេះដែលរួមបញ្ចូលទាំងទណ្ឌិតផង ថាអាចជាការត្រឹមត្រូវនោះឡើយ[10] ជាពិសេសតាមស្មារតីនៃការរកឃើញរបស់ អបជ ដែលថាមានផ្នែកផ្សេងៗទៀតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និង កតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានការពារទណ្ឌិតដែលត្រូវបានកាត់ឲ្យជាប់ទោសហើយមិនឲ្យគេជំនុំជម្រះក្ដីសារជាថ្មីម្ដងទៀតលើបទល្មើសតែមួយដដែលទៀតទេ[11]។

១២- មេធាវីការពារក្ដីបានព្យាយាមជៀសវាងកុំឲ្យមានឧបសគ្គរាំងនៅក្នុងអត្ថបទនេះ ដោយលើកទឡ្ហីករណ៍ថា *គោលការណ៍អាជ្ញាអស់ជំនុំ* ត្រូវយកមកប្រើលើគ្រប់ករណីទាំងអស់ *លើកលែងតែ* ក្នុងករណីបើសិនជាចុងចោទមិនមានបំណងចង់ឲ្យធ្វើដូចនេះ[12] ដែលជាទឡ្ហីករណ៍មួយដែលគ្មាន

---

[8] សាលដីកាសំរេចលើបណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី១២០។

[9] ឯកសារលេខ **C22/1/26**, សារណារបស់ អៀង សារី អនុលោមតាមដីកាសម្រេចលើសំណើជាបន្ទាន់របស់សហមេធាវីដែលសុំការពន្យារពេលកំណត់បន្ថែមសមស្របដើម្បីដាក់ការជំទាស់អំពីបញ្ហាទាក់ទងនឹងយុត្តាធិការ, ចុះថ្ងៃទី៧ មេសា ២០០៨, ERN 00177270-1, nn 24,28។ ឯកសារលេខ D247/1/6, បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី២៥ តុលា ២០១០, ERN 00617504, កថាខណ្ឌទី៣០។(បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី)

[10] សារណាស្ដីពី *គោលការណ៍កាត់ក្ដីពីរដងលើបទល្មើសតែមួយ*, កថាខណ្ឌទី៦។

[11] សាលដីកាសំរេចលើបណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី១២៣។

[12] សារណាស្ដីពី *គោលការណ៍កាត់ក្ដីពីរដងលើបទល្មើសតែមួយ*, កថាខណ្ឌទី៨។

មូលដ្ឋាននៅក្នុងច្បាប់កម្ពុជា ឬគ្មានតក្កភាពទាល់តែសោះ។ គ្មានមូលហេតុណាដើម្បីឲ្យធ្វើការបកស្រាយន័យនៅក្នុងមាត្រា១២ ដែលផ្ទុយពីអ្វីដែលបានចែងនៅក្នុងអត្ថបទនោះឡើយ ជាពិសេស ដូចជានៅក្នុងករណីដែលជនជាប់ចោទមិនទាន់ធ្លាប់បានឆ្លងកាត់ "ការតានតឹងនៅក្នុងចិត្តដែលទាក់ទងខាងផ្លូវចិត្ត ផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្នែកហិរញ្ញវត្ថុដែលគួបផ្សំជាមួយនឹងការកាត់ក្តីរឿងព្រហ្មទណ្ឌពីរដងនៅឡើយ"[13] ហើយ "ដោយប្រកាន់ខ្ជាប់នូវវិធាននៃច្បាប់និងគោលការណ៍ស្តីពីនីត្យានុកូលភាព"[14] មុខជានឹងបណ្តាលឲ្យខូចដោយសារតែការបកស្រាយច្បាប់កម្ពុជាដោយមិនត្រឹមត្រូវ។

១៣- ក៏ប៉ុន្តែ ទោះបីជាមាត្រា៧ ស្ថិតនៅដាច់តែឯងយ៉ាងណាក្តីក៏វាមិនមានលក្ខណៈគ្រប់គ្រាន់ជាក់លាក់ដើម្បីអាចឲ្យយកមកអនុវត្តបានដែរ។ ដូចនេះ អនុលោមតាមមាត្រា១២ នៃកិច្ចព្រមព្រៀង និងមាត្រា៣៣ថ្មី នៃច្បាប់ អវតក ឧបាស្រ័យនៅតែចាំបាច់ត្រូវឲ្យស្របទៅតាមគោលការណ៍អន្តរជាតិជាដដែល។ គោលការណ៍អន្តរជាតិទាំងនេះគឺសំរាប់នាំមុខនិយមន័យដែលនៅក្នុងវចនានុក្រមសម្រាប់ធ្វើការបកស្រាយ ដោយសារគោលការណ៍ទាំងនេះគឺជាអ្នកធានាឲ្យប្រាកដថា សវនាការជំនុំជម្រះក្តី "ត្រូវបានធ្វើឡើងស្របទៅតាមគោលការណ៍ជាធរមានដែលមានស្រាប់"[15] និងស្របតាម "បទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងស្របទៅតាមនីតិវិធីច្បាប់ត្រឹមត្រូវ"[16]។

១៤- និយមន័យដែលផ្លាស់គ្នា ដែលបានផ្តល់ឲ្យដោយមេធាវីការពារក្តីនោះគឺ ទីមួយ ការបកស្រាយមួយទៅលើច្បាប់របស់សហរដ្ឋអាមេរិក មិនមែនច្បាប់របស់កម្ពុជានោះទេ និងទីពីរ ការដាក់នូវបទដ្ឋានមួយដែលមិនស្របទៅតាមលក្ខខណ្ឌនៅក្នុងករណីរឿងនេះ។ ទោះបីជានិយមន័យរបស់មេធាវីការពារក្តីត្រូវបានយល់ព្រមហើយក៏ដោយ ក៏តម្រូវឲ្យបញ្ហានោះ "តោងតែត្រូវបានដោះស្រាយរួចឲ្យបានច្បាស់លាស់ដោយសេចក្តីសំរេចរបស់តុលាការ"។ដូចដែលសហព្រះរាជអាជ្ញាបានជូនសេចក្តីសន្និដ្ឋានកាលពីមុនហើយថា សវនាការជំនុំជម្រះក្តីឆ្នាំ១៩៧៩ គឺមិនមែនត្រូវបានបង្កើតឡើងដោយ

[13] សារណាស្តីពី *គោលការណ៍កាត់ក្តីពីរដងលើបទល្មើសតែមួយ,* កថាខណ្ឌទី១០។

[14] សារណាស្តីពី *គោលការណ៍កាត់ក្តីពីរដងលើបទល្មើសតែមួយ,* កថាខណ្ឌទី៩។

[15] មាត្រា៣៣ថ្មី, ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ("ច្បាប់ អវតក")។

[16] មាត្រា១២(២)នៃកិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង អសប")។

ច្បាប់ ឬត្រូវបានជំនុំជម្រះក្ដីដោយ "ចៅក្រម"នោះឡើយ ហើយលើសពីនេះទៅទៀតគឺមិនត្រូវបានដោះស្រាយ ឬបានចូលជាស្ថាពរនោះឡើយ។

### *បទប្បញ្ញត្តិនៅក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ*

១៥- អំណះអំណាងរបស់មេធាវីការពារក្ដីដែលថា អបជ មានការភាន់ច្រឡំថា កិច្ចការពារដូចមានចែងក្នុងមាត្រា១៤(៧) នៃអនុសញ្ញា ICCPR មានអនុភាពតែនៅក្នុងស្រុក និងថាបើដូច្នេះ មិនរារាំងការចោទប្រកាន់ អៀង សារី នោះ គឺជាការខកខានមិនបានពិចារណាឲ្យបានពេញលេញទៅលើ (១) អនុភាពនៃចរិតលក្ខណៈអន្តរជាតិរបស់ អ.វ.ត.ក និង (២) ទទួលយកវិធីសាស្ត្រក្នុងការបកស្រាយអនុសញ្ញាអន្តរជាតិ។

១៦- គេច្បាស់ណាស់ថា អ.វ.ត.ក មិនមែនជាតុលាការអន្តរជាតិ ប៉ុន្តែជាតុលាការដែលមានចរិតលក្ខណៈអន្តរជាតិមួយដែលបានបញ្ជាក់អះអាងរួចហើយដោយ អបជ និង អង្គជំនុំជម្រះសាលាដំបូង នៅក្នុងឱកាសជាច្រើន[17]។ អបជ បានអះអាងថា អ.វ.ត.ក មានលក្ខណៈ "ខុសប្លែកពីតុលាការកម្ពុជាដទៃទៀត"[18] និងថា ជា "តុលាការដាច់ដោយឡែក និងឯករាជ្យ ជាស្ថាប័នគ្មានការជាប់ទាក់ទិនទៅនឹងតុលាការដទៃទៀតណាមួយនៅក្នុងប្រទេសកម្ពុជា"[19] ។ ហេតុដូច្នេះហើយ សហព្រះរាជ

[17] អំពីឋានៈរបស់ អ.វ.ត.ក ជាតុលាការក្នុងស្រុក មេធាវីការពារក្ដីធ្លាប់បានធ្វើសារណាដ៏វែងអន្លាយរួចហើយនៅក្នុងបណ្ដឹងឧទ្ធរណ៍ដើមរបស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ (បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, ត្រង់ ERN 00617494-500) ។ ប៉ុន្តែ អបជ បានរកឃើញថា វាជាតុលាការ "មានចរិតលក្ខណៈអន្តរជាតិ" (សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ត្រង់ ERN 00661842, 00661884-7) ។ សូមអានផងដែរ ឯកសារលេខ **CF001 C5/45**, សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេចអ៊ាវ ហៅ "ឌុច", ៤ ធ្នូ ២០០៧, ERN 00154284-00154302, កថាខ័ណ្ឌទី១៨-២០ ។ ឯកសារលេខ **C11/29**, សេចក្ដីសម្រេចរបស់ អបជ ស្ដីពីបណ្ដឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល, ៤ កុម្ភៈ ២០០៨, ERN 00160734-00160742, កថាខ័ណ្ឌទី៣០ ។ ឯកសារលេខ **CF002**, សេចក្ដីសម្រេចរបស់ អបជ ស្ដីពីសហកម្មឧក្រិដ្ឋកម្មរួម, ២០ ឧសភា ២០១០, ERN 00486521-00486589, កថាខ័ណ្ឌទី១០ ។ ឯកសារលេខ **CF001 E39/5**, សេចក្ដីសម្រេចរបស់ អបជ លើសំណើសុំដោះលែង, ១៥ មិថុនា ២០០៩, ERN 00338831-00338846, កថាខ័ណ្ឌទី១១ ។

[18] ឯកសារលេខ **CF001 C5/45**, សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន កាំង ហ្គេចអ៊ាវ ហៅ "ឌុច", ៤ ធ្នូ ២០០៧, កថាខ័ណ្ឌទី១៨-២០ ។

[19] ឯកសារលេខ **C11/29**, សេចក្ដីសម្រេចរបស់ អបជ ស្ដីពីបណ្ដឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល, ៤ កុម្ភៈ ២០០៨, ERN 00160734-00160742, កថាខ័ណ្ឌទី៣០ ។

អាជ្ញាយល់ស្របតាម អបជ ដែលថាគេគ្មាន "មូលហេតុចាប់បង្ខំ... ឲ្យពិចារណាឡើងវិញអំពីសេចក្តីសន្និដ្ឋានដូច្នេះទេ"[20] ។ អបជ បានសម្រេចបញ្ជាក់អះអាងរួចហើយថា អ.វ.ត.ក "បំពេញកិច្ចការដោយខ្លួនឯងទាំងស្រុង"[21] ដោយរៀបរាប់អំពីភាពប្លែកគ្នា*យ៉ាងពិសេស* នៅ អ.វ.ត.ក ដែលស្មើនឹងសាលាក្តី*ពិសេស*ទៅទៀត ។ អាស្រ័យហេតុនេះ ភាពខុសគ្នា*យ៉ាងពិសេស* របស់ អ.វ.ត.ក នេះ ពីប្រព័ន្ធតុលាការជាតិរបស់កម្ពុជា ក៏បានទទួលស្គាល់រួចហើយដោយ អបជ តាមរយៈការហាមឃាត់ការប្រើប្រាស់មាត្រា១៤(៧) នៅ អ.វ.ត.ក ។

១៧- មេធាវីការពារក្តីតវ៉ាអំពីការពឹងផ្អែករបស់ អបជ ទៅលើការអធិប្បាយទូទៅនៅក្នុងមាត្រា១៤(៧) ដែលបានចេញដោយគណៈកម្មាធិការសិទ្ធិមនុស្ស ("HRC") ដែលបានសម្រេចថា បទប្បញ្ញត្តិនេះមិនធានាចំពោះ*គោលការណ៍គ្មានកាត់ក្តីពីរដងចំពោះបទល្មើសតែមួយ* ទាក់ទិននឹងយុត្តាធិការជាតិនៃរដ្ឋពីរ ឬ លើសពីនេះទេ ប៉ុន្តែហាមឃាត់តែការកាត់ក្តីពីរដងចំពោះបទល្មើសតែមួយ ដែលបានកាត់ក្តីរួចហើយនៅក្នុងរដ្ឋណាមួយ[22] ។ សហព្រះរាជអាជ្ញា សូមគាំទ្រចំពោះការប្រើប្រាស់របស់ អបជ នូវអធិប្បាយទូទៅរបស់ HRC លើមូលដ្ឋានដែលថា អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញានានាដែលអនុញ្ញាតឲ្យមានមធ្យោបាយបន្ថែមក្នុងការបកស្រាយ ក្នុងការកំណត់អំពីអត្ថន័យនៃបទប្បញ្ញត្តិណាដែលមិនច្បាស់លាស់ ឬ ដែលពិបាកយល់ក្នុងការបកស្រាយអនុសញ្ញានោះ[23] ។ តុលាការនានាបានពិចារណាអំពីការប្រើប្រាស់អធិប្បាយទូទៅរបស់ HRC នៅក្នុងការកំណត់អំពីអត្ថន័យនៃបទប្បញ្ញត្តិនានានៅក្នុងអនុសញ្ញា ICCPR[24] ។ ក្នុងការប្រើប្រាស់សេចក្តីអធិប្បាយនេះ

---

[20] សាលដីកាលើបណ្តឹងឧទ្ធរណ៍, ត្រង់ ERN 00661886 ។

[21] ឯកសារលេខ **CF001 C5/45**, សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេចអ៊ាវ ហៅ "ឌុច", ៤ ធ្នូ ២០០៧, ERN 00154284-00154302, កថាខ័ណ្ឌទី១៨ ។

[22] សាលដីកាលើបណ្តឹងឧទ្ធរណ៍, ត្រង់ កថាខ័ណ្ឌទី១២៨ ។

[23] មាត្រា៣២.ក, អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សិទ្ធិសញ្ញា, ២៣ ឧសភា ១៩៦៩ ។ មាត្រា៣២ នៃអនុសញ្ញាទីក្រុងវីយែន នេះ ត្រូវបានចាត់ទុកជាច្បាប់ទម្លាប់អន្តរជាតិដោយតុលាការយុត្តិធម៌អន្តរជាតិផងដែរ, *រឿងក្តីទាក់ទិននឹងអធិបតេយ្យភាពទៅលើ Pulau Ligitan និង Pulau Sipadan,* តុលាការយុត្តិធម៌អន្តរជាតិ, ១៧ ធ្នូ ២០០២, ត្រង់ 645, កថាខ័ណ្ឌទី៣៧ ។

[24] *The Queen ទល់នឹង Sin Yau-Ming* (1992) 1 HKCLR 127 ត្រង់ 141, (1991) 1 HKPLR 89 ត្រង់កថាខ័ណ្ឌទី៣ (យុត្តិសាស្ត្រក្នុងស្រុករបស់ ហុង កុង); *Cristián Daniel Sahli Vera និងគូកន ទល់នឹង Chile*, សំណុំរឿងលេខ 12.219, របាយការណ៍លេខ 43/05, Inter-Am. C.H.R., OEA/Ser.L/V/II.124 Doc. 5 (2005) ត្រង់ 39-40 ។ *Nicaragua ទល់នឹង Costa Rica,* សំណុំរឿងលេខ 1-06, របាយការណ៍លេខ 11/07, Inter-Am. C.H.R., OEA/Ser.L/V/II.130 Doc. 22, rev. 1 (2007) ត្រង់

សម្រាប់គោលបំណងនៃការបកស្រាយ តុលាការបានសម្រេចដូច្នេះថា មាត្រា១៤(៧) មិនអនុវត្តឆ្លងចំពោះយុត្តាធិការខុសៗគ្នានៅក្នុងការសម្រេចពីរទេ[25] ។ អាស្រ័យហេតុនេះ ការពឹងផ្អែករបស់ អបជ នៅលើតម្លៃនៃសេចក្តីអធិប្បាយរបស់ HRC ដ៏ជាទីពេញនិយមនេះ គឺជាការត្រឹមត្រូវ និងស្របតាមច្បាប់ និងទម្លាប់អន្តរជាតិ ។

១៨- ក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញាអនុម័តយកតាមសេចក្តីយោងនៃសេចក្តីសន្និដ្ឋានមុនៗរបស់ខ្លួនថា លក្ខខណ្ឌតម្រូវជាសារធាតុនៃមាត្រា១៤(៧) នៃអនុសញ្ញា ICCPR - ដែលថានឹងមានការកាត់ទោសជាចុងក្រោយ ឬការសម្រេចឱ្យរួចខ្លួន ស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេស - មិនបានបំពេញទេ[26]។

## *វិធាននីតិវិធីអន្តរជាតិ*

១៩- ដូចបានគូសបញ្ជាក់ដោយ HRC[27] យ៉ាងហោចណាស់ មានការខ្វែងគំនិតគ្នាអំពីអត្ថន័យនៃមាត្រា១៤(៧) មានន័យថា មាត្រានេះមិនមែនជាគោលការណ៍ដ៏ត្រឹមត្រូវមួយដែលបានទទួលស្គាល់ អាចឱ្យគេអនុវត្តបានចំពោះករណីនេះទេ ។ បើដូច្នេះ អបជ ពិតជាត្រឹមត្រូវដែលបានរកឃើញថា ច្បាប់ CCPC និង អនុសញ្ញា ICCPR មិនបានដោះស្រាយលើបញ្ហានេះទេ និងថាបើដូច្នេះ គេចាំបាច់ត្រូវពិនិត្យឡើងវិញបន្ថែមទៀតចំពោះវិធាននៃនីតិវិធីដែលបានបង្កើតក្នុងកំរិតអន្តរជាតិ ។ ដើម្បីអនុវត្តកិច្ចការនេះ សហព្រះរាជអាជ្ញាយល់ស្របថា ប្រភពដ៏ច្រើនលើសលប់ដែលបានលើកយោងដោយ អបជ បង្កើតបាននូវវិធាន "គ្រប់គ្រាន់ជាផ្លូវមួយ" ដែលថា បើសិនជាមានកំហុសជាសារវន្តណា

កថាខ័ណ្ឌទី 201; *Media Rights Agenda ទល់នឹង Nigeria*, គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន, Comm. No. 224/98 (2000) ត្រង់កថាខ័ណ្ឌទី 51 ។

[25] គណៈកម្មាធិការសិទ្ធិមនុស្ស, *សេចក្តីអធិប្បាយទូទៅ លេខ៣២: មាត្រា១៤, សិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ និងសវនាការដោយត្រឹមត្រូវយុត្តិធម៌,* ២៣ សីហា ២០០៧, CCPR/C/GC/32 ។ *AP ទល់នឹង Italy*, លេខទំនាក់ទំនង 204/1986, ២ វិច្ឆិកា ១៩៨៧ ។ *ARJ ទល់នឹង Australia*, លេខទំនាក់ទំនង 692/96, ១១ សីហា ១៩៩៧ ។

[26] ឯកសារលេខ **D427/1/17**, ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៩ វិច្ឆិកា ២០១០, ERN 00626569 ។

[27] គណៈកម្មាធិការសិទ្ធិមនុស្ស, *សេចក្តីអធិប្បាយទូទៅ លេខ៣២: មាត្រា១៤, សិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ និងសវនាការដោយត្រឹមត្រូវយុត្តិធម៌,* ២៣ សីហា ២០០៧, CCPR/C/GC/32, កថាខ័ណ្ឌទី១៩ ។

មួយកើតមានឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីជាតិ នោះ *គោលការណ៍គ្មានកាត់ក្តីពីរដងចំពោះបទល្មើសតែមួយ* មិនអនុវត្តឡើយ[28] ។

## III. ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស

### ក. សេចក្តីផ្តើម

២០- ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យមេធាវីការពារក្តីដាក់សារណាស្តីពីចំណុចបីយ៉ាងដូចជា៖[29] (១) ការបកប្រែផ្សេងគ្នានៃព្រះរាជក្រឹត្យលើកលែង ទោស និងអនុគ្រោះទោស (“RPA”)។ (២) បញ្ហាថាតើការលើកលែងទោស/អនុគ្រោះទោស ដែលបានផ្តល់ឲ្យលោក អៀង សារី ធ្វើឡើងស្របតាមច្បាប់រដ្ឋធម្មនុញ្ញដែរឬទេ។ និង (៣) ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រសិនបើនាំឲ្យមានទទ្ធីករណ៍ថ្មី។

### ខ. ការបកប្រែព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស

២១- បន្ទាប់ពីត្រូវបានអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យផ្តល់យោបល់លើការបកប្រែផ្សេងគ្នានៃព្រះរាជ-ក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ដែលត្រូវបានភាគីនានា អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង យកធ្វើជាមូលដ្ឋាន ឬយកធ្វើជាសំអាង - មេធាវីការពារក្តីលើកឡើងថា ការបកប្រែដែលភាគីនានា អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងយកធ្វើជាមូលដ្ឋាន ត្រូវតែយកមកប្រើប្រាស់ ពីព្រោះវាមានផលប្រយោជន៍ច្រើនបំផុតចំពោះជនជាប់ចោទ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ទោះបីជាមានការបកប្រែភាសាមួយចំនួនក៏ដោយ បរិបទនៃបទបញ្ញត្តិនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស មិនមានការផ្លាស់ប្តូរទេ អាស្រ័យលើឯកសារបកប្រែពិសេសដែលត្រូវបានប្រើប្រាស់។ ដូចនេះ ការប្រើប្រាស់ពាក្យពេចន៍ពិតប្រាកដនៃការបកប្រែផ្សេងគ្នា ពុំប៉ះពាល់ទាំងស្រុងលើទទ្ធីករណ៍នានាដែលគ្រប់ភាគីទាំងអស់បានបង្ហាញកាលពីមុននោះទេ ហើយក៏មិនប៉ះពាល់ទាំងស្រុងលើសេចក្តីសម្រេចដែលអង្គបុរេជំនុំជម្រះបានចេញកាលពីពេលមុននោះដែរ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញារក្សាទុកនូវទទ្ធីករណ៍កាលពីមុន

---

[28] សាលដីកាលើបណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១៥៨ ។

[29] ឯកសារ E51/8 អនុស្សារណៈស្តីពីការដាក់អញ្ញត្រកម្មបន្ថែម (ការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ ERN 00687378។

របស់ខ្លួនដែលបានធ្វើឡើង ពាក់ព័ន្ធទៅនឹងផ្នែកនេះនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស[30]។ ការបញ្ជាក់ហេតុផលសម្រាប់គោលជំហរនេះត្រូវបានសរសេរខាងក្រោមនេះ។

២២- នៅក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា អង្គបុរេជំនុំជម្រះបានផ្អែកទៅលើឯកសារបកប្រែមួយដែលខុសពីមេធាវីការពារក្ដីដែលបានប្រើប្រាស់ឯកសារបកប្រែក្រៅផ្លូវការដែលបានចេញផ្សាយតាមគេហទំព័ររបស់ អ.វ.ត.ក[31]។ អង្គបុរេជំនុំជម្រះបានលើកឡើងថា ការបកប្រែរបស់អង្គបុរេជំនុំជម្រះត្រូវបានធ្វើឡើងពេលលេញដោយអ្នក បកប្រែផ្លូវការម្នាក់ដែលមកពីអង្គភាពបកប្រែភាសា ("ITU")[32]។ លើសពីនេះទៀត អង្គជំនុំជម្រះ សាលាដំបូងបានភ្ជាប់សំណៅទីបីដែលត្រូវបានបកប្រែដោយអង្គភាពបកប្រែភាសាផងដែរ។ ឯកសារបកប្រែដែលត្រូវបានសំអាងដោយមេធាវីការពារក្ដី លើកឡើងនៅក្នុង មាត្រា ១ ថា

> **ត្រូវបានលើកលែងទោស**ឲ្យ លោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានផ្ដន្ទាទោស ប្រហារជីវិតបង់ និងរឹបអូសទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និង **អនុគ្រោះទោស** ចំពោះការកាត់សេចក្ដីក្រោមច្បាប់ស្ដីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ ០១ នស ៩៤ ចុះថ្ងៃទី ១៤ ខែកក្កដា ... [33]។[សេចក្ដីបញ្ជាក់បន្ថែម]

២៣- ភាពខុសគ្នាទីមួយដែលមេធាវីការពារក្ដីបានកត់សម្គាល់ឃើញគឺថា ឯកសារបកប្រែរបស់អង្គបុរេជំនុំជម្រះប្រើពាក្យ ការអនុគ្រោះទោស ដែលផ្ទុយទៅនឹង ការលើកលែងទោស នៅក្នុង

---

30 សូមមើលឯកសារ E51/5/3/1 ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្ម តាមវិធាន ៨៩ របស់មេធាវីការពារក្ដី ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ERN 00655302-00655337។ ឯកសារ D427/1/17 ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១០ ERN 00626531-00626650។

31 សាលដីកាលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៨៨។

32 សាលដីកាលើបណ្ដឹងឧទ្ធរណ៍ សូមមើលជើងទំព័រ ៣៨៣។

33 សារណាបន្ថែមស្ដីពីការលើកលែងទោស និងការអនុគ្រោះទោស ទំព័រ ២។

ប្រយោគទីមួយ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញកាលពីពេលមុនថា នៅក្នុងសំណៅជាភាសាខ្មែរច្បាប់ដើម ពាក្យថា "ការអនុគ្រោះទោស" ត្រូវបានប្រើប្រាស់ទាំងនៅក្នុងប្រយោគទីមួយ និងផ្នែកទីពីរនៃព្រះរាជក្រឹត្យ។ ភាពខុសគ្នាទីពីរគឺទាក់ទងទៅនឹងឯកសារបកប្រែរបស់អង្គជំនុំ ជម្រះសាលាដំបូងដែលមិនប្រើពាក្យ ការអនុគ្រោះទោស ទាល់តែសោះ គឺប្រើតែពាក្យថា ការលើកលែងទោស ប៉ុណ្ណោះ។

២៤- មេធាវីការពារក្តី ក៏ដូចជាអង្គបុរេជំនុំជម្រះ រាជរដ្ឋាភិបាលកម្ពុជា និងអង្គភាពបកប្រែភាសាផងដែរ[34] ទាំងអស់គ្នាបានលើកឡើងថា ពាក្យខ្មែរ "លើកលែងទោស" មានន័យថាជា ការអនុគ្រោះទោសផង និងជាការលើកលែងទោសផង។ យោងតាមមេធាវីការពារក្តី ភាពមានន័យមិនច្បាស់លាស់នេះអាចនាំឲ្យមាន "ភាពមិនស្របគ្នា ឬលទ្ធផលមិនប្រក្រតី"[35]។ សហព្រះរាជអាជ្ញា លើកឡើងថា មិនខ្វល់អំពីបញ្ហាថា គេប្រើពាក្យអនុគ្រោះទោស ឬលើកលែងទោសឡើយ បរិបទនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស នៅតែដដែល។ នៅក្នុងវចនានុក្រមច្បាប់ Black's Law ពាក្យថា ការអនុគ្រោះទោស ត្រូវបានឲ្យនិយមន័យថាជា "ការលើកលែងទោសដែលបានផ្តល់ឲ្យដោយរដ្ឋាភិបាលដល់មនុស្សមួយក្រុម ឬមួយប្រភេទ ដែលជាធម្មតាគឺសម្រាប់បទល្មើសនយោបាយ។ ជាអំពើនៃអំណាចអធិបតេយ្យមួយដែលបានលើកលែងទោសជាផ្លូវការ ដល់មនុស្សប្រភេទខ្លះដែលនឹងត្រូវទទួលការជំនុំជម្រះទោស ប៉ុន្តែមិនទាន់ត្រូវបានផ្តន្ទាទោសនៅ ឡើយ" រីឯពាក្យថា ការលើកលែងទោស គឺជា "អំពើ ឬចំណុចនៃការធ្វើមោឃភាពជាផ្លូវការ នូវការដាក់ទោស ឬផលវិបាកផ្លូវច្បាប់ផ្សេងទៀតនៃបទឧក្រិដ្ឋមួយ"[36]។

២៥- ផលប៉ះពាល់នៃភាពខុសគ្នាទីមួយដែលបានលើកឡើងដោយមេធាវីការពារក្តី មានការពាក់ព័ន្ធនឹងផ្នែកនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសដែលដាក់ចេញនូវការលើកលែងទោស ឬអនុគ្រោះទោស (អាស្រ័យលើការបកប្រែ) ដល់លោក អៀង សារី ចំពោះទោសប្រហារបង់ ជីវិតរបស់គាត់ និងការរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់គាត់។ មេធាវីការពារក្តីលើកឡើងថា "លើកលែងទោស" ដែលមានន័យថា "លើកលែងទោស" រួមបញ្ចូលលើសពី "ការផ្តន្ទាទោស" ពីព្រោះការ

---

[34] សារណាបន្ថែមស្តីពីការលើកលែងទោស និងការអនុគ្រោះទោស។

[35] សារណាបន្ថែមស្តីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ៥។

[36] Black's Law Dictionary បោះពុម្ពលើកទី៨ ដោយ Garner,B ទំព័រ ៩៣ និង ១១៥៤។

ផ្តន្ទាទោសណាមួយអាចត្រូវបានលើកលែង ដោយមិនមានការប៉ះពាល់ដល់ការសម្រេច ថា មានទោស ឬ ពិរុទ្ធភាពនោះទេ។ ហេតុដូច្នេះ ការលើកលែងទោស គួរតែជាពាក្យដែលត្រូវយក មកប្រើ ដោយហេតុថាពាក្យនេះអាចឱ្យគេយល់បានទូលំទូលាយជាងពាក្យថា ការអនុគ្រោះទោស។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីមិនបង្ហាញថា ពាក្យលើកលែងទោស មានន័យទូលំទូលាយជាងបែបណាឡើយ។

២៦- អត្ថន័យដែលត្រូវបានសន្មតនេះ នឹងមិនស៊ីសង្វាក់គ្នាជាមួយនឹងបរិបទនៃផ្នែកនេះនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនោះទេ ពីព្រោះផ្នែកនេះទាក់ទិននឹងការអនុគ្រោះទោស ឬលើកលែងទោសនេះ សម្រាប់តែគោលបំណងលើកលែងទោសប្រហារជីវិត និងការរឹបអូស ទ្រព្យសម្បត្តិទាំងអស់របស់គាត់ ដែលបានកំណត់តាមរយៈដីការបស់តុលាការប្រជាជនបដិវត្តន៍ប៉ុណ្ណោះ។ ការបកស្រាយការផ្តន្ទាទោសនេះទាំងមូល ត្រូវបានមេធាវីការពារក្តី ព្រះរាជអាជ្ញាពិភាក្សាគ្នារួចហើយ និងត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះរួចហើយដែរ។

២៧- ភាពខុសគ្នាទីពីរដែលមេធាវីការពារក្តីបានលើកឡើង គឺថា ការប្រើឃ្លាបកប្រែ "ការលើកលែងទោស ... ចំពោះការផ្តន្ទាទោសដែលមានចែង" នៅក្នុងច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ឆ្នាំ ១៩៩៤ ដូចដែលបានប្រើនៅក្នុងឯកសារបកប្រែរបស់អង្គជំនុំជម្រះសាលាដំបូង ជាជាងការប្រើឃ្លា "ការអនុគ្រោះទោសចំពោះការកាត់សេចក្តីក្រោមច្បាប់ឆ្នាំ ១៩៩៤" ដែលត្រូវបានអនុវត្តទាំងនៅក្នុងឯកសារបកប្រែរបស់មេធាវីការពារក្តី ទាំងនៅក្នុង ឯកសារបកប្រែរបស់អង្គបុរេជំនុំជម្រះ នឹងនាំឱ្យមានលទ្ធផលមិនសមហេតុផលមួយ[37]។ ការធ្វើ បែបនេះនឹងតម្រូវឱ្យមានការកាត់សេចក្តីមួយ និងមានការផ្តន្ទាទោសដើម្បីឱ្យមាត្រានេះមាន អានុភាព ។ ខណៈពេលដែលសហព្រះរាជអាជ្ញាឯកភាពថា ការបកប្រែនេះខុសគ្នាជាពិសេសទៅ នឹងការបកប្រែព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសកាលពីលើកមុន សហព្រះរាជ-អាជ្ញាមិនពិចារណាឃើញថា អានុភាពនេះមានភាពខុសប្លែកគ្នានោះឡើយ។ សហព្រះរាជអាជ្ញា បានលើកឡើងកាលពីមុនថា ផ្នែកនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះគឺ ទាក់ទងតែនឹងការកាត់ទោសនាពេលអនាគតពីបទរំលោភច្បាប់ឆ្នាំ ១៩៩៤ ប៉ុណ្ណោះ ប្រសិនបើអាចអនុវត្តបាន[38]។

---

[37] សារណាបន្ថែមស្តីពីការលើកលែងទោស និងការអនុគ្រោះទោស កថាខណ្ឌ ៦។

[38] ឯកសារ E51/5/3/1 ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មធ្វើតាមវិធាន ៨៩ របស់មេធាវីការពារក្តី ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ERN 00655302-00655337 កថាខណ្ឌ ៤២។

២៨- ដើម្បីជាប្រយោជន៍នៃភាពស៊ីសង្វាក់គ្នា សហព្រះរាជអាជ្ញា យល់ស្របថា ការបកប្រែមួយក្នុងចំណោមការ បកប្រែទាំងឡាយ គួរត្រូវបានទទួលយកជាផ្លូវការ និងប្រើប្រាស់ចាប់ពីពេលនេះតទៅ។ មានការ លើកឡើងថា ការប្រើប្រាស់ពាក្យ ការលើកលែងទោសនៅក្នុងផ្នែកទីមួយនៃព្រះរាជក្រឹត្យ និងពាក្យ ការអនុគ្រោះទោស នៅក្នុងផ្នែកទីពីរ ឆ្លុះបញ្ចាំងជាភាសាអង់គ្លេសនូវអត្ថន័យជាភាសាខ្មែរថា '*លើកលែងទោស* នៅក្នុងបរិបទដ៏ត្រឹមត្រូវ។ ទាក់ទិននឹងការលើកឡើងរបស់មេធាវីការពារក្តី ដែលថា ការបកស្រាយត្រូវតែជាការបកស្រាយមួយដែលផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទនោះ មានការលើកឡើងថា ពាក្យមួយណាក៏ដោយដែលត្រូវបានយកមកប្រើដោយពិចារណាទៅក្នុងបរិបទពាក្យពេចន៍ទាំងនោះនៃព្រះរាជក្រឹត្យ មានអានុភាពគតិយុត្តិដូចគ្នា។

## គ. អនុលោមភាពនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ទៅនឹងរដ្ឋធម្មនុញ្ញ

២៩- សហព្រះរាជអាជ្ញាយល់ឃើញថា ទោះបីជាព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ស្រប ឬមិនស្របទៅនឹងរដ្ឋធម្មនុញ្ញក៏ដោយ មិនគួរមានផលប៉ះពាល់ទៅលើកាតព្វកិច្ចរបស់ខ្លួនក្នុងការកំណត់អំពីសុពលភាពនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសឡើយ អនុលោម តាមមាត្រា ៤០ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ សហព្រះរាជអាជ្ញាយោងទៅលើការលើក ឡើងរបស់ខ្លួនកាលពីលើកមុន ទាក់ទិននឹងវិសាលភាពនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ហើយយល់ឃើញថា ព្រះរាជក្រឹត្យនេះមិនបានរារាំងមិនឱ្យតុលាការនេះធ្វើការចោទ ប្រកាន់រូបគាត់ឡើយ[39]។ ដូចដែលបានបញ្ជាក់កាលពីលើកមុន ការលើកលែងទោសត្រូវបានកំណត់ ត្រឹមការមិនអនុវត្តការផ្តន្ទាទោសប្រហារជីវិត និងដីការឹបអូសទ្រព្យសម្បត្តិ ដែលសម្រេចដោយ តុលាការប្រជាជនបដិវត្តន៍។ លើសពីនេះទៀត ការអនុគ្រោះទោសមិនឱ្យមានការចោទប្រកាន់អំពី បទឧក្រិដ្ឋនានាដែលត្រូវបានយកមកសំអាងនៅក្នុងច្បាប់ឆ្នាំ១៩៩៤ ពុំបានរារាំងមិនឱ្យមានការចោទប្រកាន់អំពីបទឧក្រិដ្ឋទាំងឡាយដែលត្រូវបានដាក់បញ្ចូលនៅក្នុងយុត្តាធិការនៃតុលាការនេះឡើយ[40]។

---

[39] ឯកសារ **D427/1/17** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ERN 00626531-00626650 កថាខណ្ឌ ៦១-៦៧។

[40] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦២។

៣០- គឺថា ប្រសិនបើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសត្រូវបានបកស្រាយនៅក្នុងវិធីមួយដែលមានចេតនារួមបញ្ចូលបទឧក្រិដ្ឋទាំងឡាយដែល អៀង សារី ត្រូវបានចោទប្រកាន់នៅចំពោះមុខតុលាការនេះ ប្រការនេះនឹងធ្វើឲ្យព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសអស់សុពលភាព ដោយសារតែ*បទដ្ឋានដាច់ខាត*នៃប្រភេទនៃបទឧក្រិដ្ឋទាំងនេះ បទដ្ឋានដែលពុំអនុញ្ញាតឲ្យមានបដិប្បញ្ញត្តិ[41]។ ដូច្នេះ ការអនុគ្រោះទោស ឬការលើកលែងទោសចំពោះបទឧក្រិដ្ឋទាំងនេះនឹងពុំមានសុពលភាពឡើយក្នុងច្បាប់អន្តរជាតិ និងមិនចងកាតព្វកិច្ចតុលាការនេះឡើយ[42]។ ដូចដែលបញ្ជាក់កាលពីលើកមុន សហព្រះរាជអាជ្ញាពិចារណាថា ជាតុលាការដែលមានចរិតលក្ខណៈជាតុលាការអន្តរជាតូបនីយកម្ម ដែលបានចងកាតព្វកិច្ចដោយច្បាប់អន្តរជាតិ ហើយដូច្នេះតម្រូវឲ្យអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ[43] ការលើកលែងទោសថ្នាក់ជាតិ (ទោះបីជាផ្តល់ជូនដោយមានសុពលភាពក៏ដោយ) មិនត្រូវយកមកអនុវត្ត ទាក់ទិននឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មដែលតាមគោលការណ៍អន្តរជាតិ*កំណត់ត្រូវតែផ្តន្ទាទោសដាច់ខាត* នៅចំពោះមុខតុលាការនេះបានឡើយ[44]។

## ឃ. ទឡ្ហីករណ៍ថ្មីៗ ទាក់ទិននឹងសាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

៣១- ទីបី ទាក់ទិននឹងការស្នើសុំរបស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដាក់ "ទឡ្ហីករណ៍ថ្មីៗ" ទាក់ទិននឹងសាលដីការបស់ អ.ប.ជ មេធាវីការពារក្តីបានបញ្ជាក់ថា អ.ប.ជ ភាន់ច្រឡំ ក្នុងការសម្រេចថាវិសាលភាពនៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស មិនបានការពារ អៀង សារី ពីការចោទប្រកាន់នៅ អ.វ.ត.ក ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តី បានបញ្ជាក់នូវចំណុចនេះ ដោយលើកឡើងនូវទឡ្ហីករណ៍នានាដែលត្រូវបានលើកឡើងរួចហើយ នៅក្នុងបណ្តឹង

---

[41] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា មាត្រា ៥៣ ឆ្នាំ១៩៦៩។

[42] ឯកសារ **E51/5/3/1** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៩ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ERN 00655302-00655337 កថាខណ្ឌ ៤២។

[43] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១២។ ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មាត្រា ៣៣ថ្មី

[44] សាលដីកាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២១៦។

ឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ[45]។ អ.ប.ជ បានវាយតម្លៃរួចហើយលើទឡ្ហីករណ៍ទាំងនេះ ហើយតាមរយៈការលើកឡើងនូវទឡ្ហីករណ៍ទាំងនេះម្តងទៀត ហើយបញ្ជាក់ ថា អ.ប.ជ មានការភ័ន្តច្រឡំនៅក្នុងសាលដីការបស់ខ្លួននោះ មេធាវីការពារក្តីពុំបានបង្ហាញនូវ "ទឡ្ហីករណ៍ថ្មីៗ" ណាមួយ ដូចដែលអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមាននោះឡើយ[46]។ ដើម្បីជៀសវាងនូវការលើកឡើងច្រំដែល ប្រសិនបើទឡ្ហីករណ៍ទាំងនេះត្រូវបានពិចារណា សហព្រះរាជអាជ្ញាស្នើសុំដាក់បញ្ចូលសារណាកាលពីមុនៗរបស់ខ្លួនទាក់ទិននឹងទឡ្ហីករណ៍ទាំងនេះ[47] ទៅក្នុងចម្លើយតបរួមនេះ។

## IV. សំណូមពរ

៣២- ដោយពិចារណាលើសំអាងហេតុខាងលើ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ.ប.ជ និងសារណាកាលពីមុនៗរបស់សហព្រះរាជអាជ្ញា ស្តីពីបញ្ហាទាំងនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យបដិសេធអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសរបស់ អៀង សារី និង *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |

[45] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ទំព័រ ៣៦-៤២។

[46] ឯកសារលេខ **E51/8** ការដាក់អញ្ញត្រកម្មបន្ថែម (ការលើកលែងទោស និងការអនុគ្រោះទោស អនុស្សារណៈ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១១ ERN 00687378។

[47] ឯកសារលេខ **E51/5/3/1** "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អនុលោមតាម វិធាន ៨៩" ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ERN 00655302-00655337 ។ ឯកសារលេខ **D427/1/17** "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ERN 00626531-00626650។